ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

<u>នាយកដ្ឋានព័ត៌មាន</u>

# សេចក្តីប្រកាសព័ត៌មាន
## លទ្ធផលនៃការអញ្ជើញចូលរួមសម័យប្រជុំលើកទី៧៣នៃមហាសន្និបាត អង្គការសហប្រជាជាតិ របស់ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ

*********

ចាប់ពីថ្ងៃទី ២៤ ដល់ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ២០១៨ ក្នុងអំឡុងពេលនៃសម័យប្រជុំលើកទី ៧៣ នៃមហាសន្និបាតអង្គការសហប្រជាជាតិ ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា និងគណៈប្រតិភូក្រសួងការបរទេសបានចូលរួមក្នុងកិច្ចប្រជុំជាន់ខ្ពស់នានា ដូចខាងក្រោម៖

**កិច្ចប្រជុំពិសេសរបស់រដ្ឋមន្ត្រីការបរទេសនៃរដ្ឋសមាជិកនៃសន្និសីទស្តីអំពីអន្តរសកម្មភាពនិងការកសាងទំនុកចិត្តនៅអាស៊ី (CICA) (២៤ កញ្ញា ២០១៨)**

- កម្ពុជាបានអបអរសាទរសាធារណរដ្ឋតាជីគីស្ថានដែលត្រូវបានតែងតាំងជាប្រធាន CICA សម្រាប់អាណត្តិឆ្នាំ ២០១៨-២០២០។
- កម្ពុជាបានជំរុញឱ្យបង្កើនកិច្ចខិតខំប្រឹងប្រែងដើម្បីគាំទ្រដល់ផែនការសកម្មភាព CICA សម្រាប់ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងភេរវកម្មរបស់អង្គការសហប្រជាជាតិ ដែលត្រូវបានអនុម័តដោយគណៈកម្មាធិការឧត្តមមន្ត្រី ដែលបានប្រព្រឹត្តទៅនៅខេត្តសៀមរាប ប្រទេសកម្ពុជា នៅថ្ងៃទី ២៤ ខែវិច្ឆិកាឆ្នាំ ២០១៧។
- កម្ពុជាក៏បានស្នើឲ្យពិចារណាលើការបញ្ចូលរបៀបវារៈទាក់ទងនឹងការសម្របសម្រួលពាណិជ្ជកម្មទៅក្នុងក្របខ័ណ្ឌ CICA ផងដែរ។

**កិច្ចប្រជុំកំពូលសន្តិភាពណែលសុន ម៉ែនឌែឡា (ថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៨)**

- កិច្ចប្រជុំកំពូលនេះត្រូវបានរៀបចំឡើងនៅក្នុងខួប ១០០ឆ្នាំ នៃកំណើតរបស់លោក ម៉ែនឌែឡា ដោយយោងសេចក្តីសម្រេចចិត្តលេខ៧២/២៤៣ ដែលបានអនុម័តដោយមហាសន្និបាតអ.ស.ប កាលពីថ្ងៃទី ២២ ខែធ្នូ ឆ្នាំ២០១៧ ដើម្បីឧទ្ទិសដល់ស្នាដៃគាត់ដែលបានចំណាយពេលពេញ



អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខ័ណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 214 441, 216 122
ទូរសារ : (855) 23 216 144, 216 141
អ៊ីម៉ែល : mfaic@mfa.gov.kh

មួយជីវិត ចូលរួមចំណែកក្នុងការស្វែងរកលទ្ធិប្រជាធិបតេយ្យ និងការជំរុញវប្បធម៌សន្តិភាព នៅជុំវិញពិភពលោក។

- កម្ពុជា ជាមួយនឹងបណ្តារដ្ឋសមាជិកដទៃទៀត បានអនុម័តសេចក្តីប្រកាសនយោបាយ ដោយប្តេជ្ញាអនុវត្ត "ការគោរពគ្នាទៅវិញទៅមក ភាពអត់អោន ការយោគយល់ និងការផ្សះផ្សានៅក្នុងទំនាក់ទំនងរវាងប្រជាជាតិ" និងបានកំណត់យក "អំឡុងពេលចាប់ពីឆ្នាំ ២០១៩ ដល់ឆ្នាំ ២០២៨ ជាទសវត្សរ៍សន្តិភាពណែលសុន ម៉ែនឌែឡា"។

កិច្ចប្រជុំជាន់ខ្ពស់ស្តីពីការផ្តល់ហិរញ្ញវត្ថុសម្រាប់របៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (ថ្ងៃទី២៤ ខែ កញ្ញា ឆ្នាំ ២០១៨)

- កិច្ចប្រជុំនេះ ផ្តោតជាសំខាន់លើយុទ្ធសាស្ត្រថ្មីរបស់អគ្គលេខាធិការអ.ស.ប. ដើម្បីគាំទ្រដល់ការផ្តល់ហិរញ្ញវត្ថុដល់របៀបវារៈឆ្នាំ២០៣០ ដែលបានស្នើឲ្យមានសកម្មភាពដើម្បីសម្រេចគោលដៅ ៣គឺ ទី១ ការបន្សុីគ្នារវាងគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសកល ជាមួយនឹងរបៀបវារៈឆ្នាំ២០៣០ ទី២ ការជំរុញយុទ្ធសាស្ត្រហិរញ្ញវត្ថុប្រកបដោយចីរភាពក្នុងកម្រិតតំបន់ និងតាមប្រទេសនីមួយៗ និងទី៣ ការស្វែងរកនវានុវត្តន៍ហិរញ្ញវត្ថុ បច្ចេកវិទ្យាថ្មីៗ និងឌីជីថលូបនីយកម្ម ដើម្បីធានាឲ្យមានការទទួលបានហិរញ្ញវត្ថុប្រកបដោយសមធម៌។

កិច្ចប្រជុំជាន់ខ្ពស់ស្តីពីសកម្មភាពដើម្បីរក្សាសន្តិភាព(ថ្ងៃទី២៥ ខែ កញ្ញា ឆ្នាំ ២០១៨)

- កិច្ចប្រជុំជាន់ខ្ពស់នេះធ្វើឡើងដើម្បីប្រារព្ធខួបលើកទី ៧០ នៃប្រតិបត្តិការរក្សាសន្តិភាពអ.ស.ប.។
- អគ្គលេខាធិការអ.ស.ប. បានរំលឹកអំពីការធ្វើទស្សនកិច្ចរបស់គាត់ទៅសាធារណរដ្ឋអាហ្វ្រិកកណ្តាល កាលពីឆ្នាំ២០១៧ ដែលនៅទីនោះលោកបានដាក់កម្រងផ្កាឧទ្ទិសដល់កងរក្សាសន្តិភាពរបស់កម្ពុជា និងម៉ារ៉ុក ដែលត្រូវបានសម្លាប់នៅទីនោះ។
- ក្នុងនាមជាអ្នកចូលរួមចំណែកយ៉ាងសកម្មក្នុងប្រតិបត្តិការរក្សាសន្តិភាព កម្ពុជាបានសំដែងការគាំទ្រចំពោះ "គំនិតផ្តួចផ្តើមស្តីពីសកម្មភាពដើម្បីរក្សាសន្តិភាព" ដែលមានគោលបំណងពង្រឹងបេសកកម្មរក្សាសន្តិភាពឲ្យកាន់តែខ្លាំង និងមានសុវត្ថិភាព និងប្រមែប្រមូលការគាំទ្រផ្នែកនយោបាយ ដើម្បីឲ្យមានការផ្តល់នូវបរិក្ខារ និងការបណ្តុះបណ្តាលប្រសើរជាងមុនសម្រាប់កងរក្សាសន្តិភាព។ មកទល់ពេលនេះ កម្ពុជាស្ថិតនៅក្នុងចំណោមរដ្ឋទាំង១៤៦ ដែលបានគាំទ្រ "សេចក្តីប្រកាសស្តីពីការប្តេជ្ញារួមលើប្រតិបត្តិការរក្សាសន្តិភាពរបស់អ.ស.ប." ។

កិច្ចប្រជុំរដ្ឋមន្ត្រីនៃចលនាមិនចូលបក្សសម្ព័ន្ធ (ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ ២០១៨)

- ប្រទេសកម្ពុជាបានរួមគ្នាអនុម័តសេចក្តីប្រកាសនយោបាយស្តីពី "ការគាំពារធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និង គោលបំណងនិងគោលការណ៍របស់ចលនាមិនចូលបក្សសម្ព័ន្ធ៖ ឆ្ពោះទៅរកវប្បធម៌សន្តិភាព"។

- កម្ពុជាបានសម្តែងការព្រួយបារម្ភអំពីការកើនឡើងនៃនិន្នាការជ្រៀតជ្រែកកិច្ចការផ្ទៃក្នុង ដោយបំពាននឹងធម្មនុញ្ញអ.ស.ប.។
- កម្ពុជាក៏បានទាញការយកចិត្តទុកដាក់ចំពោះសន្តិភាពដែលមានអាយុកាល២០ឆ្នាំ ដែលកម្ពុជាសម្រេចបាន ហើយដែលជាសន្តិភាពយូរជាងគេបំផុតពុំធ្លាប់មាននៅក្នុងប្រវត្តិសាស្ត្រសម័យទំនើបរបស់ខ្លួន។ វប្បធម៌សន្តិភាពរបស់កម្ពុជាអាចស្ថិតស្ថេរទៅបាន លុះត្រាតែមានការបង្រួបបង្រួមជាតិ និងការលើកកម្ពស់ស្មារតីឈ្នះ-ឈ្នះ ដែលដាក់ផលប្រយោជន៍ជាតិ និងប្រជាជនធ្វើជាស្នូល។ ដូច្នេះហើយ កម្ពុជាបានអំពាវនាវឲ្យមានការគោរពអធិបតេយ្យភាព និងការលើកកម្ពស់ការរួមរស់ដោយមិត្តភាព និងកិច្ចសហប្រតិបត្តិការឈ្នះ-ឈ្នះរវាងប្រជាជន និងប្រជាជាតិ ព្រោះថាការជ្រៀតជ្រែកពីបរទេសមិនដែលជាកត្តាជំរុញឲ្យមានសន្តិភាពប្រកបដោយចីរភាពនោះទេ។

កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីប្រចាំឆ្នាំនៃបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច(ថ្ងៃទី២៦ខែកញ្ញាឆ្នាំ ២០១៨)

- ប្រទេសកម្ពុជាបានស្វាគមន៍ប្រទេសម៉ាឡាវីដែលបានធ្វើជាប្រធានប្តូរវេនថ្មីនៃបណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច(LDC)។ កម្ពុជាក៏បានស្វាគមន៍ផងដែរនូវការបង្កើតធនាគារបច្ចេកវិទ្យាសម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច នៅក្នុងប្រទេសតួកគី នៅក្នុងខែមិថុនា ឆ្នាំ ២០១៨។
- កម្ពុជាបានអំពាវនាវដល់គ្រប់ភាគីពាក់ព័ន្ធ ឱ្យប្តេជ្ញាអនុវត្ត "កម្មវិធីសកម្មភាពទីក្រុងអ៊ីស្តង់ប៊ុលសម្រាប់បណ្តាប្រទេសដែលមានការអភិវឌ្ឍតិចតួច"(IPoA) ដើម្បីដោះស្រាយបញ្ហាប្រឈមជាលក្ខណៈស្ថាប័នដែលបណ្តាប្រទេសទាំងនោះបានជួបប្រទះ ដើម្បីលុបបំបាត់ភាពក្រីក្រ និងសម្រេចគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព។
- កម្ពុជាក៏បានសម្តែងការព្រួយបារម្ភចំពោះភាពមិនប្រាកដប្រជា សម្រាប់បណ្តាប្រទេសមានការអភិវឌ្ឍតិចតួច ដោយសារតែការកាត់បន្ថយក្របខ័ណ្ឌអនុគ្រោះនានា ដូចជាកម្ចី ជំនួយឥតសំណង និងជំនួយអភិវឌ្ឍន៍ ដែលអាចប៉ះពាល់ដល់ការសំរេចបាននូវកំណើនសេដ្ឋកិច្ច ទន្ទឹមគ្នានឹងការទទួលស្គាល់ភាពចាំបាច់ដើម្បីឲ្យបណ្តាប្រទេសទាំងនោះមានភាពជាម្ចាស់ ដើម្បីត្រៀមខ្លួនចាកចេញពីឋានៈជាប្រទេសដែលមានការអភិវឌ្ឍតិចតួច។

កិច្ចប្រជុំប្រចាំឆ្នាំលើកទី ៤២ របស់រដ្ឋមន្ត្រីការបរទេសនៃក្រុមប្រទេស G-៧៧ (ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០១៨)

- កម្ពុជាបានចូលរួមជាមួយសមាជិកដទៃទៀតដើម្បីអបអរសាទរប៉ាឡេស្ទីនចំពោះការជាប់ឆ្នោតដើម្បីដឹកនាំក្រុមប្រទេស G-៧៧ ក្នុងឆ្នាំ ២០១៩ ។
- អង្គប្រជុំបានអនុម័តសេចក្តីប្រកាសថ្នាក់រដ្ឋមន្ត្រី និងបានពិភាក្សាអំពីផលប៉ះពាល់នៃបញ្ហាទាក់ទងនឹងការងាររបស់យុវជន និងសមត្ថភាពផលិត។
- កម្ពុជាបានគូសបញ្ជាក់ថា ការវិនិយោគទៅលើវិស័យអប់រំ រួមចំណែកដល់សន្តិភាពប្រកបដោយនិរន្តរភាពនៅទូទាំងពិភពលោក។ តាមរយៈផែនការយុទ្ធសាស្ត្រអប់រំថ្នាក់ជាតិ កម្ពុជាស្នើរតែ

សម្រេចបានកម្រិតសកលនូវការទទួលបានការអប់រំថ្នាក់បឋមសិក្សា ហើយកំពុងបង្កើនសមភាពយេនឌ័រ។ កម្ពុជាក៏បានលើកឡើងអំពីសារៈសំខាន់នៃចំណេះដឹងផ្នែកកុំព្យូទ័រក្នុងការផ្ដល់ឱកាសអភិវឌ្ឍអាជីព និងវិជ្ជាជីវៈដល់យុវជននៅទូទាំងពិភពលោកក្នុងយុគសម័យឌីជីថល។

**កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន-សម្ព័ន្ធប៉ាស៊ីហ្វិកលើកទី ៥ (ថ្ងៃទី ២៦ ខែកញ្ញា ឆ្នាំ២០១៨)**

- កិច្ចប្រជុំបានធ្វើការកត់សម្គាល់អំពីវឌ្ឍនភាព ក្នុងការអនុវត្តផែនការការងារអាស៊ាន-សម្ព័ន្ធប៉ាស៊ីហ្វិក(២០១៧-២០១៨) និងបានព្រមព្រៀងបន្តពេលវេលាអនុវត្តផែនការការងារនេះរហូតដល់ខែធ្នូ ឆ្នាំ២០១៩។
- កិច្ចប្រជុំបានយល់ឃើញអំពីភាពចាំបាច់ ក្នុងការពង្រឹងសហប្រតិបត្តិការក្នុងការតភ្ជាប់ឌីជីថល និងការតភ្ជាប់រូបវន្ត មានជាអាទិ៍៖ ការតភ្ជាប់ផ្លូវហោះហើរត្រង់រវាងតំបន់ទាំងពីរ ការបង្កើនការយល់ដឹងរបស់ប្រជាជននៃតំបន់ទាំងពីរនិងការគាំទ្រសហគ្រាសមីក្រូ ធុនតូច និងមធ្យម។ បន្ថែមលើនេះ កិច្ចប្រជុំក៏បានសង្កត់ធ្ងន់អំពីសារៈសំខាន់ក្នុងការលើកកម្ពស់ការបំពេញឲ្យគ្នាទៅវិញទៅមក រវាងចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០២៥ និងចក្ខុវិស័យយុទ្ធសាស្ត្រសម្ព័ន្ធប៉ាស៊ីហ្វិកឆ្នាំ២០៣០។

**កិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការរដ្ឋឈូងសមុទ្រ (ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៨)**

- កិច្ចប្រជុំបានឯកភាពឲ្យបញ្ចប់នូវឯកសារក្របខ័ណ្ឌនៃកិច្ចសហប្រតិបត្តិការអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការរដ្ឋឈូងសមុទ្រ (២០១៩-២០២៣)។
- កិច្ចប្រជុំយល់ថា មានភាពចាំបាច់ត្រូវរៀបចំដំណើរការឡើងវិញនូវក្រុមការងារតាមវិស័យទី៦ នៃអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការរដ្ឋឈូងសមុទ្រ ជាពិសេស ពាណិជ្ជកម្មនិងវិនិយោគ អប់រំ វប្បធម៌និងព័ត៌មាន សន្តិសុខស្បៀង និងការវិនិយោគកសិកម្ម ថាមពល និងទេសចរណ៍។
- កិច្ចប្រជុំនេះ ក៏បានឯកភាពឲ្យមានការរៀបចំប្រជុំកិច្ចថ្នាក់រដ្ឋមន្ត្រីការបរទេសអាស៊ាន-ក្រុមប្រឹក្សាសហប្រតិបត្តិការរដ្ឋឈូងសមុទ្រ នៅក្នុងកម្រិតត្រីភាគី នៅរៀងរាល់២ឆ្នាំម្ដង និងកិច្ចប្រជុំរវាងលេខាធិការដ្ឋាននៃតំបន់ទាំងពីរ នៅរៀងរាល់ឆ្នាំ។

**កិច្ចប្រជុំក្រៅផ្លូវការរដ្ឋមន្ត្រីការបរទេសអាស៊ាន និងសហរដ្ឋអាមេរិក (ថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ២០១៨)**

- កិច្ចប្រជុំបានពិភាក្សាប្រកបដោយផ្លែផ្កា ស្ដីពីការពិនិត្យតាមដាននូវលទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន និងសហរដ្ឋអាមេរិក ដែលបានប្រព្រឹត្តទៅកាលពីខែសីហា ឆ្នាំ២០១៨ នៅប្រទេសសិង្ហបុរី និងការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ាន-សហរដ្ឋអាមេរិកលើកទី៦ នៅខែវិច្ឆិកា ឆ្នាំ២០១៨ ខាងមុខ។
- កិច្ចប្រជុំបានសរសើរតួនាទីដ៏សំខាន់ និងការរួមចំណែកដ៏មានលក្ខណៈស្ថាបនារបស់អាមេរិក ក្នុងការលើកស្ទួយសន្តិភាព សន្តិសុខ ស្ថិរភាព និងវិបុលភាពតំបន់។ កិច្ចប្រជុំបានទទួលស្គាល់នូវ

សារៈសំខាន់នៃការពង្រឹងភាពជាដៃគូសេដ្ឋកិច្ច ការតភ្ជាប់ផ្នែកឌីជីថល កម្មសិក្សារបស់យុវជន សហគ្រិនភាព ការអប់រំ ព្រមទាំងការពង្រីកការតភ្ជាប់រវាងតំបន់ទាំងពីរ។

- កិច្ចប្រជុំបានស្វាគមន៍នូវការវិវត្តជាវិជ្ជមាននៅឧបទ្វីបកូរ៉េ ជាពិសេស កិច្ចប្រជុំកំពូលអន្តរកូរ៉េ និង កិច្ចប្រជុំកំពូលជាប្រវត្តិសាស្ត្ររវាងសហរដ្ឋអាមេរិក និងសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ។

កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ (IAMM) និងកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានជាមួយនឹងអគ្គលេខាធិការអ.ស.ប និងប្រធានមហាសន្និបាតអ.ស.ប. លើកទី ៧៣ (AUMM) (ថ្ងៃទី ២៨ ខែកញ្ញា ឆ្នាំ ២០១៨)

- កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ានក្រៅផ្លូវការ បានធ្វើការកត់សម្គាល់នូវបញ្ជីបេក្ខភាពអាស៊ាន នៅក្នុងស្ថាប័នអង្គការសហប្រជាជាតិ និងអង្គការអន្តរជាតិនានា។ កម្ពុជាបានថ្លែងអំណរគុណសារជាថ្មីចំពោះបណ្តាប្រទេសសមាជិកអាស៊ានទាំងអស់ ដែលបានគាំទ្រកម្ពុជាជាសមាជិកក្រុមប្រឹក្សាសេដ្ឋកិច្ច-សង្គមរបស់អ.ស.ប.(ECOSOC) សម្រាប់អាណត្តិឆ្នាំ២០១៩ និងជាអនុប្រធាននៃសម័យប្រជុំលើកទី៧៣នៃមហាសន្និបាតអ.ស.ប ចាប់ពីខែកញ្ញា ឆ្នាំ២០១៨ ដល់ខែកញ្ញា ឆ្នាំ ២០១៩។ រដ្ឋមន្ត្រីការបរទេសអាស៊ាន បានធ្វើការផ្លាស់ប្តូរទស្សនៈទៅវិញទៅមកអំពីបញ្ហាតំបន់ និងអន្តរជាតិ ដែលជាកង្វល់រួម និងបានស្តាប់អំពីបច្ចុប្បន្នភាពនៃស្ថានការណ៍មនុស្សធម៌នៅរដ្ឋរ៉ាក់ខាញនៃសាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា។
- កិច្ចប្រជុំ AUMM បានផ្តោតសំខាន់លើការពង្រឹងកិច្ចសហប្រតិបត្តិការអាស៊ាន-អ.ស.ប. និងបានពិនិត្យវាយតម្លៃការអនុវត្តផែនការសកម្មភាព ដើម្បីអនុវត្តសេចក្តីប្រកាសរួមស្តីពី ភាពជាដៃគូគ្រប់ជ្រុងជ្រោយរវាងអាស៊ាននិងអង្គការសហប្រជាជាតិ (២០១៦-២០២០)។ កិច្ចប្រជុំបានស្វាគមន៍កិច្ចខិតខំប្រឹងប្រែងរបស់ស្ថាប័នជំនាញតាមផ្នែកនីមួយៗរបស់អាស៊ាន និងទីភ្នាក់ងារនានារបស់អ.ស.ប. ក្នុងការបង្កើតវិធានការជាក់លាក់ ដើម្បីសម្របសម្រួលការអនុវត្តផែនការសកម្មភាពប្រកបដោយប្រសិទ្ធភាព។ កិច្ចប្រជុំក៏បានកត់សម្គាល់អំពីសារៈសំខាន់នៃការអនុវត្តផែនការការងារទី៣នៃគំនិតផ្តួចផ្តើមសម្រាប់សមាហរណកម្មអាស៊ាន និងផែនការមេស្តីពីការតភ្ជាប់អាស៊ានឆ្នាំ២០២៥ និងបានធ្វើការកត់សម្គាល់ផងដែរ អំពីសារៈសំខាន់ពិសេសនៃការបង្កើនកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលអាស៊ានសម្រាប់សកម្មភាពមីន ដែលមានមូលដ្ឋាននៅរាជធានីភ្នំពេញ និងទីភ្នាក់ងារជំនាញនានារបស់អង្គការសហប្រជាជាតិ។

ថ្ងៃ ព្រហស្បតិ៍ ១០រោច ខែភទ្របទ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
ភ្នំពេញ ថ្ងៃទី០៤ ខែ តុលា ឆ្នាំ ២០១៨